**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia

Nation Religion King

♦♦♦♦♦♦

# វិធានមូលដ្ឋានស្ដីពីដំណើរការដោះស្រាយវិវាទតាមការសម្រុះសម្រួល រវាង សហគមន៍ភូមិពូទឹត ភូមិពូលុ ភូមិប៊ូស្រា និងក្រុមហ៊ុនសុកហ្វីន

## Ground Rules on Land Conflict Resolution through Mediation Process between Pu Teut, Pu Lu, Busra Villages and Socfin Company

វិវាទដីធ្លីរវាងសហគមន៍ភូមិពូទឹត សហគមន៍ភូមិពូលុ និងសហគមន៍ភូមិប៊ូស្រា ជាមួយក្រុមហ៊ុនសុកហ្វីន បានកើតឡើងតាំងពីឆ្នាំ២០០៩ ដោយអូសបន្លាយរហូតមកដល់បច្ចុប្បន្ននេះនៅមិនទាន់មានដំណោះស្រាយណាមួយដែលអាចទទួលយកបានជាផ្លូវការសម្រាប់ភាគីទាំងពីរ ទើបបណ្ដាលឲ្យវិវាទទាំងនេះវាបានក្លាយជាវិវាទមួយដ៏រ៉ាំរ៉ៃ ។

Land Conflicts between Pu Teut, Pu Lu and Busra community and Socfin company can be considered a cyclic conflict that first erupted in 2009. Without proper and effective resolutions, the land conflicts resurfaced up to now.

ទោះបីជាភាគីក្រុមហ៊ុន និងភាគីសហគមន៍ទទួលស្គាល់ថាធ្លាប់បានខ្នះខ្នែងព្យាយាមដោះស្រាយវិវាទរបស់ខ្លួនជាច្រើនលើកច្រើនសារមកហើយក្ដី តាមរយៈគណៈកម្មាការត្រីភាគី និងកម្មវិធីផ្ដល់សំណងជូនដល់សហគមន៍ ប៉ុន្តែវិវាទរវាងភាគី ទាំងពីរនៅតែបន្ត និងមិនអាចដោះស្រាយបានចប់សព្វគ្រប់នៅឡើយ។

Despite the fact that both the company and the community have tried to resolve the land conflicts many times through the establishment of a tri-partite committee and through compensation payment programs to household claimants, the conflicts still resurfaced and to this day active.

ដោយហេតុថាភាគីទាំងពីរមិនទាន់យល់នូវបញ្ហាវិវាទឲ្យបានស៊ីជម្រៅ និងជាក់លាក់នោះ ហើយចង់បានការដោះស្រាយមួយប្រកបដោយជោគជ័យ ឆាប់រហ័ស សន្តិវិធី និងរក្សាបាននូវការរាប់អានគ្នាទៅថ្ងៃអនាគតបន្តទៀតនោះ ទើបភាគីទាំងពីរធ្វើការជ្រើសរើសយកនូវការដោះស្រាយតាមរយៈការសម្រុះសម្រួលនេះឡើង។

Given the fact that both parties fail to fully and deeply understand the issue, that they want a quick, effective and non-violent resolution and that they want to continue living harmoniously with one another in the future, they agree to use mediation as a mean of resolving their land conflicts.



ព្រះរាជាណាចក្រកម្ពុជា
ហ្គោ
GO Co., Ltd.
ទីស្នាក់ការរាជធានីភ្នំពេញ

ការដោះស្រាយវិវាទតាមរយៈការសម្រុះសម្រួល បានផ្តល់ឱកាសអោយភាគីទាំងពីរយល់បានច្បាស់នូវបញ្ហាវិវាទរបស់ខ្លួនជាក់លាក់ និងច្បាស់លាស់ ដោយការបង្កើតផែនទីវិវាទដែលមានការចូលរួមពីគ្រប់ភាគីដែលពាក់ព័ន្ធ ការបង្កើតជាក្រុម និងជ្រើសរើសតំណាង សម្រាប់ដោះស្រាយតាមប្រភេទវិវាទនីមួយៗរបស់សហគមន៍។ ការដោះស្រាយតាមប្រភេទវិវាទនីមួយៗនេះ វាក៏បង្កើតនៅភាពងាយស្រួលក្នុងការយល់នូវបញ្ហាបានជាក់លាក់ អាចអោយភាគីនីមួយៗចូលរួមបញ្ចេញមតិ និងលើកឡើងនៅបញ្ហារបស់ខ្លួនតាមរយៈតំណាងក្រុមនីមួយៗ។ យន្តការនេះ ក៏អាចជួយឲ្យចំណេញពេលវេលាក្នុងការប្រកបរបរចិញ្ចឹមជីវិត និងមិនប៉ះពាល់ដល់ពេលវេលារបស់ភាគីដ៏ទៃ ដែលមិនពាក់ព័ន្ធនឹងករណីវិវាទ។

Resolving land conflicts through mediation gives an opportunity for both parties to fully and clearly understand their conflict given the fact that mediation involves creating conflict maps in which all relevant stakeholders were asked to participate, creating groups and selecting representatives for each category of the conflict. This has therefore made it very convenient for both parties to clearly understand the issue, express their opinions and raise their own issues through their designated representatives. This resolution mechanism also saves time for both parties giving them opportunity to earn a living and in the meantime does not affect that of others.

ភាគីសហគមន៍ភូមិពូទឹត ភូមិពូលុ ភូមិប៊ូស្រា និងក្រុមហ៊ុនសុកហ្វីន មានបំណងចង់ឲ្យមានការស្មើភាពគ្នា និងការគោរពគ្នាទៅវិញទៅមកក្នុងការដោះស្រាយវិវាទរបស់ខ្លួន តាមរយៈការសម្រុះសម្រួល ទើបឯកភាពគ្នាបង្កើតនៅវិធានមូលដ្ឋានសម្រាប់ការសម្រុះសម្រួលនេះឡើង ដើម្បីជាបទបញ្ញាផ្ទៃក្នុងមួយសម្រាប់ភាគីទាំងពីរ ក៏ដូចជាអ្នកពាក់ព័ន្ធដទៃទៀតត្រូវធ្វើការគោរពតាមក្នុងកំឡុងពេលនៃដំណើរការសម្រុះសម្រួលវិវាទរវាងភាគីទាំងពីរ។

Pu Teut, Pu Lu and Busra community and Socfin company wish to resolve their land conflicts in an equal and respectful manner through mediation. With this reason, both parties agree to create These Ground Rules for Mediation as an internal regulation for themselves as well as for other relevant stakeholders to abide by during the mediation process.

**តំណាងសហគមន៍ ភូមិពូទឹត ភូមិពូលុ ភូមិប៊ូស្រា និងក្រុមហ៊ុនសុកហ្វីន ឯកភាពលើលក្ខខណ្ឌដូចខាងក្រោម៖**

**Representatives of Pu Teut, Pu Lu and Busra community and Socfin company hereby agree:**

## ប្រការ១/Article 1. គោលបំណង និងគោលការណ៍/Purposes and Principles

**១.១.គោលបំណង៖**

១.១.១. ចង់ស្វែងរកដំណោះស្រាយទាំងអស់គ្នា ឲ្យបានសម្រេច និងឆាប់រហ័ស។

១.១.២. ចង់បានទំនាក់ទំនងក្នុងនាមជាមួយអ្នកជិតខាងនឹងគ្នា សហការគ្នា និងយោគយល់គ្នាទៅវិញទៅមក។

១.១.៣. ចង់ឲ្យក្រុមហ៊ុនដោះស្រាយដីដែលពាក់ព័ន្ធ ជាមួយប្រជាពលរដ្ឋឲ្យបានទាន់ពេលវេលា

១.១.៤. ចង់ឲ្យមានដំណោះស្រាយស្មើភាពគ្នារវាងក្រុមហ៊ុន និងប្រជាពលរដ្ឋឲ្យឆាប់រហ័ស សូមធ្វើដោយស្ម័គ្រចិត្ត ស្មោះត្រង់ជាមួយប្រជាពលរដ្ឋ។

**1.1 Purposes:**

1.1.1. Seek a quick and effective solution for both sides.



ព្រះរាជាណាចក្រកម្ពុជា ហ្គោ GO Co., Ltd. ស្នាក់ការរាជធានីភ្នំពេញ

1.1.2. Seek a good relationship in the spirit of good neighbors, cooperation and understanding.

1.1.3. Expect the company to solve the land-related conflict for the communities on time.

1.1.4. Expect fair solutions for both company and communities based on the principles of consent and honesty with the communities.

**១.២.គោលការណ៍ ៖**

១.២.១. ភាគីយល់ព្រមធ្វើសកម្មភាពដោយស្មោះត្រង់ដោះស្រាយបញ្ហាដីធ្លី អហិង្សា គ្មានការគំរាមកំហែង គោរពគ្នាទៅវិញទៅមក មានភាពស្មើគ្នា មានប្រសិទ្ធភាពខ្ពស់ ធ្វើឡើងដោយស្ម័គ្រចិត្ត និងស្មោះត្រង់ដោះស្រាយដីធ្លី គ្មានការបង្ខិតបង្ខំ ព្រមទាំងត្រូវអនុវត្តស្របតាមច្បាប់កម្ពុជា។

១.២.២. ក្នុងកំឡុងពេលដំណើរការសម្រុះសម្រួល ដែលរៀបចំដោយអង្គការ IMG កំពុងបន្ត ភាគីណាមួយមិនអាចចូលរួមនៅក្នុងដំណើរការមួយផ្សេងទៀតស្របពេលជាមួយគ្នា ក្នុងគោលបំណងដោះស្រាយបញ្ហាដែលបានលើកឡើង នៅក្នុងពាក្យបណ្តឹងបានទេ (ហាមធ្វើការប្តឹងគ្នាទៅវិញទៅមករវាងភាគីទាំងពីរ)។

**1.2. Principles:**

1.2.1. Both parties agree to work with one another based on the principles of honesty to resolve land conflict, non-violence, mutual respect, equality, effectiveness and consent in order to solve the land conflicts without coercion from any party and in accordance with Cambodian laws.

1.2.2. During the mediation process organized by IMG, each of the two parties shall not simultaneously engage in other processes in order to solve the conflict (One party shall not file lawsuit complaints against the other).

**ប្រការ ២/ Article 2. អ្នកតំណាងតាមផ្លូវច្បាប់/ Elected Representatives**

២.១. សហគមន៍នីមួយៗ៖

២.១.១. អាចរើសតំណាងស្របច្បាប់០៣(បី)នាក់ ឬ០៥(ប្រាំ)នាក់ សម្រាប់ដំណើរការសន្ទានកម្ម(សម្រុះសម្រួល) នេះ

២.១.២. ជ្រើសរើសតំណាងតាមក្រុមនៃវិវាទចំនួន០៣(បី)នាក់ ឬ០៥(ប្រាំ)នាក់ ក្នុងមួយក្រុមរួមមាន៖

- ក្រុមតំណាងសម្រាប់ករណីដីរួមសហគមន៍(ដីបម្រុងទុក, ដីព្រៃដំណម, ដីព្រៃអភ័ក្ស និងព្រៃកប់ខ្មោចជាដើម) ចំនួន ០៥(ប្រាំ)នាក់
- ក្រុមតំណាងសម្រាប់ករណីចំការពាក់ព័ន្ធដែលមិនទាន់បានដោះស្រាយ ចំនួន ០៣(បី)នាក់ ឬ ០៥ (ប្រាំ)នាក់
- ក្រុមតំណាងសម្រាប់ករណីចំការកៅស៊ូគ្រួសារ ចំនួន ០៣(បី)នាក់
- ក្រុមតំណាងសម្រាប់ករណីចំការ ឬដីតាមដងអូរ (គាត់ហៅថា ចំការជាក់ស្តែង) ចំនួន ០៣(បី)នាក់

២.១.៣. ចំនួនតំណាងនៃក្រុមនីមួយៗច្រើនបំផុតសម្រាប់គ្រប់ករណីមិនឲ្យលើសពី ចំនួន ០៥(ប្រាំ)នាក់។

២.២. ភាគីក្រុមហ៊ុន អាចជ្រើសរើសអ្នកតំណាងស្របច្បាប់របស់ខ្លួនច្រើនបំផុតចំនួន ០៥(ប្រាំ) នាក់។



ព្រះរាជាណាចក្រកម្ពុជា ហ្គោ GO Co., Ltd.

2.1. Each community:

2.1.1. Can select three or five elected representatives for the mediation process.

2.1.2. Choose three or five representatives for each of the land conflicts categories, including:

- Five representatives for communal land cases (Reserved land, Spiritual forest, Burial land, etc.).
- Three or five representatives for planation land cases that have not been solved,
- Three representatives for family rubber plantation cases
- Three representatives for groups with plantation land located along the stream (local people called it 'currently cultivated land'

2.1.3. Select no more than five representatives for land conflict category.

2.2. The company can select its own legal representatives up to 5

## ប្រការ ៣/ Article 3. ដំណើរការនៃកិច្ចប្រជុំ/Meeting Process

៣.១. ក្នុងករណីមានកិច្ចប្រជុំរួមធំៗរវាងក្រុមហ៊ុន និងសហគមន៍ទាំងមូល ភូមិនីមួយៗត្រូវធ្វើការតែងតាំងឲ្យមានវត្តមានអ្នកតំណាងស្របច្បាប់របស់ខ្លួនចំនួន០៣នាក់ ឬ ០៥(ប្រាំ)នាក់ដើម្បីចូលរួមលើដំណើរការនៃកិច្ចប្រជុំសម្រុះសម្រួលនេះ។

៣.២. កិច្ចប្រជុំតូចៗ ឬប្រជុំដោយឡែក៖ ភាគីនឹងចាត់តាំងតំណាងស្របច្បាប់របស់ខ្លួនសម្រាប់ចូលរួមក្នុងមួយក្រុមអោយបានម្នាក់។

៣.៣. អ្នកតំណាងត្រូវធ្វើការប្រជុំផ្សព្វផ្សាយ អំពីពត៌មានផ្សេងៗនៃកិច្ចប្រជុំ ដល់សមាជិកក្រុមដែលពាក់ព័ន្ធ ឬដល់សមាជិកសហគមន៍របស់ខ្លួនដែលពាក់ព័ន្ធ។

3.1. In case there is a big meeting between the company and the communities, each village shall nominate three or five representatives in order to participate in the mediation process.

3.2. For small meetings or separate meetings, each party shall nominate at least one representative to take part.

3.3. The representatives shall meet and disseminate the information that come out of the various meetings to their relevant group members or community members.

## ប្រការ ៤/ Article 4. ការធ្វើសេចក្ដីសម្រេចចិត្ត/Decision Making

៤.១. អ្នកតំណាងស្របច្បាប់មានសិទ្ធិសម្រេចចិត្ត និងយល់ព្រមលើបញ្ហាណាមួយ សម្រាប់សន្ទានកម្ម(សម្រុះសម្រួល)នេះក្នុងនាមខ្លួនជាអ្នកតំណាងស្របច្បាប់សម្រាប់ភូមិនីមួយៗ (ពូទឹត ឬពូលុ ឬប៊ូស្រា) ឬ ជាតំណាងស្របច្បាប់របស់ក្រុមហ៊ុន។

៤.២. នៅក្នុងកិច្ចប្រជុំសម្រុះសម្រួល អ្នកតំណាងអាចធ្វើការសម្រេចចិត្ត ដោយឈរលើការឯកភាពជារួម ពោលគឺ២នាក់ក្នុងចំណោម ៣នាក់(២/៣) ឬ៣នាក់ក្នុងចំណោម៥នាក់(៣/៥)។ ប៉ុន្តែមុននឹងការឯកភាពរបស់អ្នកតំណាង



ព្រះរាជាណាចក្រកម្ពុជា ហ្គោ GO Co., Ltd.

ត្រូវបានចងជាកាតព្វកិច្ចព្រមព្រៀងជាមួយភាគីម្ខាងទៀត អ្នកតំណាងត្រូវសុំការគាំទ្រពីក្រុមសមាជិករបស់ខ្លួន ក្នុង រយៈពេល២០(ម្ភៃ)ថ្ងៃ គិតពីថ្ងៃប្រជុំឯកភាព។

៤.៣. សុពលភាពនៃការអនុវត្តសេចក្តីសម្រេចស្ថាពរ៖ ក្នុងករណីមានការផ្ទេរដី (តាមរយៈការទិញ ការជួល មរតក ឬតាមរូបភាពផ្សេងៗទៀត) សេចក្តីសម្រេចរបស់គូភាគី នឹងត្រូវមានសុពលភាពដដែល ហើយត្រូវបានផ្ទេរបន្តទៅកាន់ម្ចាស់ដី ឬអ្នកកាន់កាប់ដីថ្មី ឬអ្នកទទួលសិទ្ធិបន្តរបស់ភាគីទាំងពីរ ឬសន្តិជន ឬអ្នកទទួលស្នងមរតកនោះ។ គូភាគីចំពោះមុខសេចក្តីសម្រេចនេះ មានកាតព្វកិច្ចជម្រាបអ្នកទទួលសិទ្ធិបន្ត អំពីកាតព្វកិច្ចក្នុងការអនុវត្តតាមសេចក្តីសម្រេចនេះ ហើយរាល់កំណត់ត្រាដែលពាក់ព័ន្ធ នឹងត្រូវបានភ្ជាប់ជាមួយនឹងប្លង់ដីជាឯកសារឧបសម្ព័ន្ធ។ យ៉ាងណាមិញ ក្នុងករណីដែលម្ចាស់ដីថ្មី ឬអ្នកកាន់កាប់ដីថ្មី មិនបានអនុវត្តតាមសេចក្តីសម្រេចនេះ នោះភាគីដែលបានចុះហត្ថលេខាទទួលស្គាល់សេចក្តីសម្រេច នឹងមិនត្រូវបានចងកាតព្វកិច្ចឲ្យទទួលខុសត្រូវលើករណីនេះឡើយ ប្រសិនបើខ្លួនបានបំពេញកាតព្វកិច្ចរបស់ខ្លួនដូចបានចែងខាងលើ។

4.1. The selected representatives have the rights to make decisions and agree on certain issues during the mediation process, in their capacity as legal representatives of each village (Pu Teut, Pu Lu and Busra village) or the legal representatives of the company.

4.2. During the mediation process, the representatives can make decisions based on a joint agreement, meaning with the agreement of 2 of the 3 (2/3) or 3 of the 5 (3/5) representatives. But before such decisions become binding agreements with the other parties, the representatives need to ask for support/confirmation from their group members within 20 days, starting from the day the decisions were made.

4.3. Longevity of the validity of the agreement: In the case of land transfer (through purchase, lease inheritance or other arrangements), the agreements by the parties shall remain valid and be transferred to new landowner or landholder, successor or heir. Parties to the agreement are obliged to inform the successor of the land holding rights of their obligation to comply with the agreement, and the documentation of the agreement will be attached as annex to the land certificate. However, in case the new landowner or landholder does not comply with the agreement, the signatories to the agreement will not be held accountable, provided they have complied with the obligations as stated above.

## **ប្រការ ៥/Article5 រយៈពេលនៃដំណើរសន្ធានកម្ម (សម្រុះសម្រួល)/Duration of the mediation process**

៥.១. ភាគីទាំងពីរមានគោលបំណងបញ្ចប់ដំណើរការឲ្យបានត្រឹម១០(ដប់)ខែគិតចាប់ពីថ្ងៃចុះហត្ថលេខា ឬស្នាមមេដៃលើការព្រមព្រៀងចំពោះវិធានមូលដ្ឋាននេះតទៅ។

៥.២. ក្នុងករណីដែលមិនអាចដំណោះស្រាយ ក្នុងរយៈពេល ១០ (ដប់)ខែនេះ ភាគីអាចពន្យាររយៈពេលនៃការសម្រុះសម្រួលរហូតដល់ការបញ្ចប់បញ្ហា តាមកិច្ចព្រមព្រៀងរបស់គូភាគីជាលាយលក្ខណ៍អក្សរ។

5.1. Both parties intend to solve the land conflicts through mediation within the period of 10 months, starting from the date These Ground Rules is signed and thumb-printed.

5.2. If the solutions cannot be reached within this period of 10 months, both parties can extend the mediation period until the problems are solved through written agreement by both parties.



GO Co., Ltd.

**ប្រការ ៦/Article6 .ទីប្រឹក្សា ឬអ្នកពិគ្រោះយោបល់ ៖/ Advisors or Counsellors**

៦.១. អង្គការ និង/ ឬ មេធាវីដែលដើរតួជាទីប្រឹក្សា ឬអ្នកពិគ្រោះយោបល់របស់ភាគីទាំងពីរ ត្រូវមានការទទួលស្គាល់តាមផ្លូវច្បាប់ក្នុងនាមជាមេធាវី, ឬអង្គការដែលបានចុះបញ្ជីតាមផ្លូវច្បាប់។

៦.២. ទីប្រឹក្សាឬអ្នកពិគ្រោះយោបល់ នឹងធ្វើការសង្កេតលើដំណើការសន្ទនា នៅក្នុងពេលសម្រុះសម្រួល និងការស្នើសុំឲ្យមានការឈប់សម្រាក ដើម្បីផ្តល់ដំបូន្មានជូនអ្នកតំណាងភាគី ទៅតាមភាពចាំបាច់។

៦.៣. អ្នកតំណាង/ភាគីនៅក្នុងការសម្រុះសម្រួល អាចស្នើសុំមតិយោបល់ពីទីប្រឹក្សា ឬអ្នកពិគ្រោះយោបល់ ទៅតាមភាពចាំបាច់។

៦.៤. ទីប្រឹក្សា ឬអ្នកពិគ្រោះយោបល់ អាចផ្តល់សញ្ញាដល់អ្នកតំណាងភាគី នៅពេលដែលពួកគេមានបំណងចង់ផ្តល់មតិយោបល់។

៦.៥. អាចមានទីប្រឹក្សា ឬអ្នកពិគ្រោះយោបល់ ច្រើនបំផុត ចំនួន ០៥(ប្រាំ)នាក់។

៦.៦. ទីប្រឹក្សា ឬអ្នកពិគ្រោះយោបល់ គ្រប់រូបនឹងត្រូវបានស្នើសុំឲ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងរក្សាការសម្ងាត់មួយ។

6.1. Organizations and/or lawyers acting as advisors or counsellors for the two parties shall be those recognized by laws or legally registered.

6.2. The advisors or counsellors will observe the conversation between the two parties during mediation, and they have the rights to request for a break session so that they can provide advice to their party representatives.

6.3. The representatives/parties in the mediation might ask for advice from the advisors or counsellors at any time.

6.4. Advisors or counsellors can give signals to the representatives when they think they need to give advice to them.

6.5. There can be a maximum of five advisors or counsellors.

6.6. All advisors or counsellors will be required to sign a confidentiality agreement.

**ប្រការ ៧/ Article7 .អ្នកសង្កេតការណ៍ /Observers**

៧.១. ការចូលរួមរបស់អ្នកសង្កេតការណ៍ ត្រូវមានការយល់ព្រមពីភាគីទាំងសងខាងជាមុនសិន មុនពេលអនុញ្ញាតឲ្យចូលរួមកិច្ចប្រជុំ។

៧.២. អ្នកសង្កេតការណ៍គ្រប់រូបនឹងត្រូវបានស្នើសុំ ឲ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងរក្សាការសម្ងាត់មួយ ដែលកិច្ចព្រមព្រៀងនោះនឹងចងភាតព្វកិច្ចពួកគេ ទៅនឹងល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងវិធានមូលដ្ឋានទាំងនេះ។

៧.៣. តំណាងសហគមន៍ អាចអញ្ជើញចាស់ទុំភូមិច្រើនបំផុត០២(ពីរ)នាក់ មកធ្វើជាអ្នកសង្កេតការណ៍ក្នុងពេលចរចាបាន ក្នុងករណីគ្មានចាស់ទុំ អ្នកតំណាងស្របច្បាប់ដែលមិនមានឈ្មោះក្នុងក្រុមសម្រាប់ការចរចា អាចធ្វើជាអ្នកសង្កេតការណ៍បាន។



ព្រះរាជាណាចក្រកម្ពុជា ហ្គោ GO Co., Ltd. ទីស្នាក់ការរាជធានីភ្នំពេញ

7.1. Participation of observers in the mediation process shall be agreed beforehand by both parties.

7.2. All observers will be required to sign the confidentiality agreement that will oblige them to abide by the conditions stated in These Ground Rules for Mediation.

7.3. Community representatives might invite up to two elders from their villages to act as observers during the negotiation process. In case that there is no any elderly, the elected representatives who do not have the name in list of the negotiation group can be the observers.

## ប្រការ ៨/ Article8 .អាជ្ញាធររដ្ឋាភិបាល/Authority

៨.១. ក្នុងករណីដែលភាគីឯកភាពគ្នាថា ការចូលរួមរបស់អាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធ(អាជ្ញាធរថ្នាក់ស្រុក និងឃុំ)មានភាពចាំបាច់ ភាគីអាចអញ្ជើញមន្ត្រីតំណាងរបស់ពួកគាត់ឲ្យចូលរួមដល់ដំណើរការនេះបាន ។

៨.២. សន្ធានការី ឬអ្នកសម្រុះសម្រួល (IMG) នឹងបន្តជូនដំណឹងដល់អាជ្ញាធររដ្ឋាភិបាលថ្នាក់ស្រុក និងឃុំ អំពីដំណើរការតាមការឯកភាពរបស់គូភាគីទាំងសងខាង។

៨.៣. មន្ត្រីអាជ្ញាធរថ្នាក់ស្រុក និងឃុំ ត្រូវបានអញ្ជើញចូលរួមក្នុងការដោះស្រាយវិវាទតាមការសម្រុះសម្រួល ក្នុងនាមជាអ្នកសង្កេតការ និងជាសាក្សី។

8.1. In case both parties agree that the participation of relevant government authority (district and commune level authority) is necessary, they can invite their representative officials to participate in the process.

8.2. The mediator (IMG) shall disseminate the information about the mediation process to district and commune authorities, upon approval from both parties.

8.3. Authorities should be invited to be observers and witness in the conflict resolution through mediation process.

## ប្រការ ៩/Article9. អ្នកសម្រុះសម្រួល ឬ សន្ធានការី/Mediators

៩.១. អង្គការ IMG នឹងរៀបចំកិច្ចប្រជុំសម្រុះសម្រួល ដោះស្រាយវិវាទរវាងភាគីសហគមន៍ និងភាគីក្រុមហ៊ុន ។

៩.២. អ្នកសម្រុះសម្រួលក៏អាចរៀបចំកិច្ចប្រជុំទ្វេភាគីដាច់ដោយឡែកជាមួយភាគីណាមួយ ទៅតាមភាពចាំបាច់។ ក្នុងករណីនេះ អ្នកសម្រុះសម្រួលគ្រាន់តែជូនដំណឹងទៅភាគីម្ខាងទៀតថា ខ្លួននឹងជួបប្រជុំជាមួយភាគីមួយទៀត និងពេលវេលានៃការជួបប៉ុណ្ណោះ។ អ្នកសម្រុះសម្រួលមានសិទ្ធិរក្សាទុកនូវព័ត៌មាន ដែលភាគីម្ខាងៗបានផ្តល់មកឲ្យខ្លួនជាការសម្ងាត់ ហើយអាចផ្តល់នូវការសម្ងាត់នេះទៅភាគីម្ខាងទៀតបាន លុះត្រាតែមានការឯកភាពជាលាយលក្ខណ៍អក្សរពីភាគីអ្នកផ្តល់ការសម្ងាត់នោះ។

9.1. IMG will organize mediation meetings in order to help solve the land conflicts between the company and the communities.

9.2. The mediators might also organize separate meetings with particular party when necessary. In such case, they only need to inform the other party about the meeting and time of the meeting. The mediators have the rights to make obtained information confidential and shall disclose this



ព្រះរាជាណាចក្រកម្ពុជា ហ្គោ GO Co., Ltd.

information to the other party only when there is a written consent from the party giving the information.

**ប្រការ ១០/Article10. ការចងក្រងឯកសារអំពីកិច្ចប្រជុំ និងការព្រមព្រៀង/Documentation and Agreement**

១០.១. កិច្ចប្រជុំនីមួយៗនឹងមានសេចក្ដីសង្ខេបជាលាយលក្ខអក្សរមួយច្បាប់ ដោយភ្ជាប់នូវបញ្ជីឈ្មោះរបស់អ្នកចូលរួម និងអ្នកតំណាងទាំងអស់។

១០.២. ភាគី ឬអ្នកតំណាងនឹងត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងបណ្ដោះអាសន្ន និងការព្រមព្រៀងដែលត្រូវបានសម្រេចចុងក្រោយ ដើម្បីឲ្យស្របតាម ប្រការ ៤ ចំនុច ៤.២ខាងលើ។

១០.៣. រាល់ចំណុចដែលបានទទួលការព្រមព្រៀងគ្នារវាងគូភាគី នឹងត្រូវបានធ្វើជាកិច្ចព្រមព្រៀងជាលាយលក្ខអក្សរទុកជាភស្តុតាង។

10.1. After each meeting, there shall be a written summary, attached with a list of all participants and representatives.

10.2. The conflict parties or representatives shall sign a temporary agreement and a final agreement reached by both parties so as to comply with Article 4 Section 4.2 stated above.

10.3. All points agreed upon by both parties during the negotiation process shall be made into a written agreement as evidence.

**ប្រការ ១១/Article11 .បញ្ហា របៀបវារៈ និងរចនាសម្ព័ន្ធ/Issues, Agenda and Structure**

១១.១.បញ្ហា៖ ភាគី(តំណាងសហគមន៍ និងតំណាងក្រុមហ៊ុន) នឹងមានការព្រមព្រៀងលើបញ្ហាមួយចំនួន ដែលត្រូវលើកមកពិភាក្សាក្នុងដំណើរការសម្រុះសម្រួល។

១១.២. របៀបវារៈ៖ របៀបវារៈនឹងគួរតែកំណត់ជាមុនដោយអង្គការ IMG មុនពេលចាប់ផ្ដើមនៃកិច្ចប្រជុំនីមួយៗ ឬចរចា។

១១.៣. ភាគីទាំងពីរត្រូវព្រមព្រៀងគ្នា ថា៖ ការដោះស្រាយវិវាទទៅតាមលំដាប់ពីលេខ១ដល់លេខ៤ ដូចខាងក្រោម៖

1. ដីរួមសហគមន៍(ដីព្រៃបំរុង, ដីព្រៃដំណាម, ដីព្រៃអារក្ស និងដីកប់ខ្មោច)
2. ដីចំការកៅស៊ូគ្រួសារ
3. ដីពាក់ព័ន្ធមិនទាន់ដោះស្រាយ ឬមិនទាន់ទទួលបានសំណង
4. ដីចំការ ឬដីស្រែជាក់ស្ដែងតាមដងអូរ

១១.៤. ភាគីទាំងពីរ នឹងផ្ដោតលើការសម្រុះសម្រួលវិវាទ តាមលំដាប់បញ្ហាដែលបានលើកឡើងខាងលើ។

១១.៥. ក្នុងករណីចាំបាច់ ភាគីអាចកែសម្រួលទៅលើរបៀបវារៈនោះ នៅពេលចាប់ផ្ដើមកិច្ចប្រជុំនីមួយតាមការព្រមព្រៀងគ្នារបស់គូភាគី។

១១.៦. រចនាសម្ព័ន្ធ៖ ភាគីនឹងព្រមព្រៀងលើរបៀបសម្រុះសម្រួល ដែលនឹងអនុវត្តដោយការិយាល័យ IMG។

11.1. Issues: conflict parties (Community representatives and company representatives) shall agree on issues that will be brought to the negotiation table during the mediation process.



GO Co., Ltd.

11.2. Agenda: Agenda shall be prepared in advance by IMG prior to each meeting or negotiation process.

11.3. The parties agree to work to resolve the issues based on the following order from 1 to 4:

1. Communal land (Reserved land, Spiritual forest, and Burial land)
2. Family rubber plantations
3. Land conflict that have not been resolved or whose owners have not been compensated
4. Farm or rice field along streams

11.4. Both parties will focus their efforts on solving the conflict based on the aforementioned order of priority.

11.5. The agenda might be modified as necessary prior to the commencement of each meeting, upon the approval from both parties.

11.6. Structure: Both parties shall agree on the mediation procedures or processes prepared by IMG.

**ប្រការ ១២/Article12 . ភាសាដែលប្រើសម្រាប់ដំណើរការនៃកិច្ចប្រជុំសម្រុះសម្រួល/Languages Used in the Mediation Process**

១២.១. រាល់អ្នកតំណាងគ្រប់រូប អាចនិយាយជាភាសាដើមកំណើតរបស់ខ្លួនបាន ជាភាសាព្នង ភាសាខ្មែរ ឬភាសាអង់គ្លេសជាដើម។

១២.២. អង្គការ IMG នឹងផ្តល់ការបកប្រែភាសាសមស្រប សម្រាប់ដំណើរការសម្រុះសម្រួល។

១២.៣. រាល់ឯកសារទាំងអស់ដែលប្រើប្រាស់ក្នុងការសម្រុះសម្រួល នឹងមានការបកប្រែជាពីរភាសា (ភាសាអង់គ្លេស និងភាសាខ្មែរ)។

12.1. Elected representatives may speak their native languages, namely Bunong, Khmer or English.

12.2. IMG will provide appropriate translation for the mediation process.

12.3. All documents used in the mediation process shall be translated into two languages, namely Khmer and English.

**ប្រការ ១៣/Article13 .ការចំណាយនៃកិច្ចប្រជុំ/Meeting Expenditure**

១៣.១. អង្គការ IMG នឹងប្រើប្រាស់ថវិការបស់ម្ចាស់ជំនួយ (MRLG) ដើម្បីរ៉ាប់រងលើថ្លៃចំណាយសម្រាប់ដំណើរការនៃការសម្រុះសម្រួល ដូចជាថ្លៃបន្ទប់ប្រជុំ និងថ្លៃចំណាយដោយផ្ទាល់សមស្របដទៃទៀត ក្នុងការរៀបចំដំណើរការសម្រុះសម្រួល។

១៣.២. អង្គការ IMG ក៏នឹងប្រើប្រាស់ថវិការបស់ម្ចាស់ជំនួយ (MRLG) គាំទ្រទៅលើថ្លៃចំណាយចាំបាច់ ដូចជាថ្លៃធ្វើដំណើរ ថ្លៃអាហារនិង ស្នាក់នៅ សម្រាប់ភាគីសហគមន៍ និងអាជ្ញាធរមូលដ្ឋានផងដែរ។



ព្រះរាជាណាចក្រកម្ពុជា ហ្គោ GO Co., Ltd. ទីស្នាក់ការរាជធានីភ្នំពេញ

13.1. IMG will use the fund from donor (MRLG) to cover all expenses incurred during the mediation process such as meeting room rental, and other direct costs so as to facilitate the mediation process.

13.2. IMG will use the fund from donor (MRLG) to cover basic expenses, including transportation cost, food, and hotel expense for the communities and local authorities.

**ប្រការ ១៤/Article14 . ការប្រាស្រ័យទាក់ទង និងប្រព័ន្ធផ្សព្វផ្សាយ/Communication and Media**

១៤.១. អ្នកតំណាងប្តេជ្ញាថា ព័ត៌មានដែលទទួលបានពីកិច្ចប្រជុំនីមួយៗនឹងត្រូវចែករំលែកឲ្យបានពេញលេញជាមួយក្រុម ដែលខ្លួនតំណាងនីមួយៗរបស់ខ្លួន តាមរយៈការប្រើប្រាស់សេចក្តីថ្លែងការណ៍រួមដែលមានការឯកភាពពីគូភាគី វិវាទ ឬសេចក្តីសម្រេចដែលមានការឯកភាពដើម្បីឲ្យអ្នកតំណាងអាចស្នើសុំការយល់ព្រមពីសមាជិកក្រុមនីមួយៗ។

១៤.២.ក្នុងករណីដែលភាគីវិវាទណាមួយ ទីប្រឹក្សា និងអ្នកសង្កេតការណ៍មានបំណងចង់ធ្វើការប្រាស្រ័យទាក់ទងទៅខាងក្រៅ អំពីដំណើរការសម្រុះសម្រួលនេះ ពួកគេអាចធ្វើទៅបាន តាមរយៈការប្រើប្រាស់សេចក្តីថ្លែងការរួមដែលភាគីវិវាទទាំងអស់បានឯកភាពគ្នា ។

14.1. Representatives are committed to making sure that all the information obtained from the meeting shall be fully shared with the groups that they represent using a joint statement or an agreement agreed by both parties so that the representatives can obtain the approval from each member of the groups later.

14.2. In case any conflict party, advisors and observers wish to communicate to the outsiders about the mediation process, they may do so by using a joint statement agreed by both parties.

**ប្រការ ១៥/Article15 .ការរក្សាការសម្ងាត់/Confidentiality**

១៥.១. ខ្លឹមសារនៃកិច្ចពិភាក្សានៅក្នុងកិច្ចប្រជុំ និងរាល់ឯកសារទាំងឡាយណាដែលត្រូវបានចែករំលែកក្នុងលក្ខណៈជាការសម្ងាត់ នឹងត្រូវចាត់ទុកជាព័ត៌មានសម្ងាត់និងឯករាជ្យរវាងភាគី និងមិនគប្បីចែករំលែកជាមួយសាធារណជនទូទៅ ឬប្រព័ន្ធផ្សព្វផ្សាយដោយគ្មានការអនុញ្ញាតពីភាគីទាំងពីរឡើយ។

១៥.២. អ្នកតំណាងនឹងចាត់វិធានការណ៍សមស្រប ធ្វើយ៉ាងណាឲ្យសមាជិកក្រុម ឬអ្នកពាក់ព័ន្ធរបស់ពួកគាត់ បានយល់និងគោរព និងអនុវត្តតាមតាម ប្បញ្ញត្តិស្តីពីការរក្សាការសម្ងាត់នេះដែរ។

15.1. All the content in the meetings and all confidential documents shared only between the conflict parties shall not be shared with the general public or mass media unless there is a consent from both parties.

15.2. Representatives shall take appropriate measure to ensure that their group members or other stakeholders abide by this provision of confidentiality as well.

ព្រះរាជាណាចក្រកម្ពុជា ហ្គោ GO Co., Ltd. ...

**ប្រការ ១៦/Article16 ការអនុវត្តស្របតាមវិធានមូលដ្ឋាន/Implementation of the Ground Rules**

១៦.១. ភាគី (សហគមន៍ និងក្រុមហ៊ុន) អ្នកសម្រុះសម្រួល ទីប្រឹក្សា និង អ្នកសង្កេតការណ៍ យល់ព្រម និងឯកភាពអនុវត្តស្របតាមវិធានមូលដ្ឋានទាំងនេះ។

១៦.២. ក្នុងករណីដែលភាគីមួយជឿថា ភាគីម្ខាងទៀតធ្វើខុសដោយបានរំលោភបំពានវិធានមូលដ្ឋាន ភាគីនោះត្រូវជូនដំណឹងដល់អ្នកសម្រុះសម្រួល ដើម្បីឲ្យអ្នកសម្រុះសម្រួលស្វែងរកដំណោះស្រាយចំពោះស្ថានភាពបែបនេះ។

១៦.៣. ក្នុងករណីការសម្រុះសម្រួលមិនទទួលបានលទ្ធផល ភាគីមួយអាចជូនដំណឹងទៅភាគីម្ខាងទៀត ថាខ្លួនលែងមានបំណង ឬអារម្មណ៍បន្តការសម្រុះសម្រួល និងលែងជាប់កាតព្វកិច្ចចំពោះវិធានមូលដ្ឋានតទៅទៀតហើយ។

16.1. conflict parties (communities and company), mediators, advisors and observers shall agree to implement and abide by these ground rules for mediation.

16.2. In case a party finds out that the other party has violated the Ground Rules, that party shall inform the mediators so that the latter can address the problems accordingly.

16.3. If the mediation does not produce results, a party can inform the other party that they do not have intention or feeling to continue the mediation process and will not be bound by the Ground Rules any longer.

**ប្រការ ១៧/Article17 - ឆន្ទៈ សមត្ថភាពរបស់ភាគី និងភាសាដែលប្រើក្នុងវិធានមូលដ្ឋាន/Willingness, Ability and Languages Used in the Ground Rules**

១៧.១. ភាគីទាំងពីរមានឆន្ទៈរួមគ្នាបង្កើតនូវវិធានមូលដ្ឋាននេះឡើង ដោយគ្មានការបង្ខិតបង្ខំ គំនាប ឬការគម្រាមកំហែងពីភាគីណាមួយនោះឡើយ។

១៧.២. ភាគីក្រុមហ៊ុនយល់ព្រមអនុញ្ញាតឲ្យមានការបកប្រែជាវិជ្ជាជីវៈ និងជាលាយលក្ខណ៍អក្សរ នូវវិធានមូលដ្ឋាននេះពីភាសាខ្មែរមកជាភាសាអង់គ្លេស ដើម្បីឲ្យភាគីក្រុមហ៊ុន បានយល់នូវខ្លឹមសារលម្អិតរបស់ឯកសារនេះ។

១៧.៣. ភាគីទាំងពីរបានអាន បានស្តាប់យល់ បានយល់ដឹង និងឯកភាពនូវខ្លឹមសារក្នុងគ្រប់ប្រការ នៃវិធានមូលដ្ឋាននេះ និងសន្យាថានឹងអនុវត្តគ្រប់ប្រការទាំងអស់នៃវិធានមូលដ្ឋាននេះឲ្យបានត្រឹមត្រូវ និងស្របតាមច្បាប់ ចាប់ពីពេលចុះកិច្ចព្រមព្រៀងនេះតទៅ ។

១៧.៤. វិធានមូលដ្ឋាននេះត្រូវធ្វើឡើងជាភាសាខ្មែរ និងមានការបកប្រែជាភាសាអង់គ្លេស ចំនួន ០៧ (ប្រាំពីរ)ច្បាប់ នៃភាសានីមួយៗ ហើយគ្រប់ច្បាប់ទាំងនេះត្រូវចាត់ទុកជាលិខិតតួបករណ៍តែមួយ និងដូចៗគ្នា។ ក្នុងករណីមានភាពខុសគ្នារវាងអត្ថបទជាភាសាខ្មែរ និងអត្ថបទជាភាសាអង់គ្លេស ភាសាខ្មែរត្រូវប្រើជាអត្ថបទគោលក្នុងការបកស្រាយវិធានមូលដ្ឋាននេះ។

17.1. These Ground Rules are created upon joint willingness of both parties, free from coercion, pressure or threats from any party.

17.2. The company allows to have the Ground Rules professionally translated and certified from Khmer to English so that the company party can understand the detailed content of the document.



ព្រះរាជាណាចក្រកម្ពុជា ហ្គោ GO Co., Ltd. ក្រុមហ៊ុនការងារបកប្រែ

17.3. Both parties have read, heard clearly, understood and agreed to the content of each article in These Ground Rules and are committed to implementing and abiding by the Ground Rules in accordance with the laws, starting from the day the Ground Rules document is signed.

17.4. The Ground Rules are prepared in Khmer and translated into English in 07 (seven) copies of each language, and all copies are considered a single instrument of equal value. In case there are mismatches in the interpretation between Khmer and English documents, the former shall prevail.

**ប្រការ ១៨/Article18. ការផ្លាស់ប្តូរទៅលើវិធានមូលដ្ឋាន និងប្រសិទ្ធិភាពអនុវត្ត/Modification of Ground Rules and Effectiveness of the Implementation**

១៨.១.ភាគីអាចធ្វើការផ្លាស់ប្តូរទៅលើវិធានមូលដ្ឋាននេះបាន លុះត្រាមានការឯកភាពជារួមពីភាគីទាំងសងខាង (សហគមន៍ និង ក្រុមហ៊ុន) ហើយការផ្លាស់ប្តូរទាំងឡាយត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានការចុះហត្ថលេខា ឬផ្តិតស្នាមមេដៃដោយគូភាគីទាំងពីរ។

១៨.២.វិធានមូលដ្ឋាននេះនឹងត្រូវចុះហត្ថលេខាដោយ៖ គូភាគីទាំងពីរ ទីប្រឹក្សា អ្នកសង្កេតការណ៍ និង អ្នកសម្រុះសម្រួល IMG ដើម្បី ទុកជាសក្ខីភាពចំពោះមុខច្បាប់តទៅ។

១៨.៣.វិធានមូលដ្ឋាននេះនឹងមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា ឬផ្តិតស្នាមមេដៃរបស់គូភាគីទាំងពីរនេះតទៅ។

១៨.៤.វិធានមូលដ្ឋាននេះធ្វើឡើងជា០៧(ប្រាំមួយ)ច្បាប់ដើម ដែលមានតម្លៃស្មើគ្នា ដោយ ០៣(បី)ច្បាប់សម្រាប់ភាគីតំណាងសហគមន៍ (ភូមិពូទឹត ០១ច្បាប់ ភូមិ ពូលុ ០១ច្បាប់ និងភូមិប៊ូស្រា ០១ច្បាប់), ០១(មួយ)ច្បាប់ទៀតសម្រាប់ភាគីក្រុមហ៊ុន និង ០១(មួយ)ច្បាប់ តម្កល់នៅការិយាល័យ IMG, ០១(មួយ)ច្បាប់តម្កល់នៅអង្គការសហប្រជាជាតិ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា និង០១(មួយ)ច្បាប់តម្កល់នៅសាលាស្រុក ពេជ្រាដា។

18.1. Any party can modify the Ground Rules only when there is an approval from the conflict parties (Communities and Company), and those modifications shall be made in written and signed or thumb-printed form by those two parties.

18.2. These Ground Rules will be signed by both conflict parties, advisors and the IMG mediators as evidence under the law from now on.

18.3. These Ground Rules shall come into effect starting from the day it is signed or thumb-printed by both parties.

18.4. These Ground Rules are made into 07 (seven) original copies of equal validity, three (3) copies for community representatives (01 for Pu Teut, 01 for Pu Lu and 01 for Busra village, respectively), 1(one) copy for the company, 1(one) copy for IMG, 1(one) copy for the United Nations Office of High Commissioner of Human Rights in Cambodia and the other 1(one) copy for Pechrada District Hall.

សែនមនោរម្យ,ថ្ងៃទី20.. ខែ ..កុម្ភៈ........ឆ្នាំ២០១៨

Sen Monorom, Date.20 Month02..Year: 2018

ហ្គោ

GO Co., Ltd.

## ហត្ថលេខា ឬស្នាមមេដៃស្តាំ
Signature or Thumbprint

### ភាគីសហគមន៍
### Community Party

**សហគមន៍ភូមិពូទឹត**
Pu Teut Community

ង៉ាន យីន
Ngang Yin

ធីន ស៊ីម៉ា
Thin Sima

ធឿន ម៉ាប់
Theoun Mab

គប់ លេត
Korb Let

កេត ផល្លិត
Ket Phallit

ម៉ាស ឌីម

**សហគមន៍ភូមិពូលុ**
Pu Lu Community

ភ្លឹង ធេ
Ploeng The

ងេះ ណាំ
Nges Noam

ឈឹង វឿង
Chhoeng Voeurng

មឿល ងែវ
Moeurl Ngev

ព្យើល នៀន
Pyoeurl Nien

**សហគមន៍ភូមិប៊ូស្រា**
Busra Community

ប្រុង ទើច
BrongToeurch

ឆើច បែន
Chhoeurch Ben

ប៉ាក់ ឃឿន
Pak Khoeun



ព្រះរាជាណាចក្រកម្ពុជា
ហ្គោ
GO Co., Ltd.

| | |
|---|---|
| អ្នកសម្រុះសម្រួល<br>Mediator | ភាគីក្រុមហ៊ុន<br>Company Party |
| លោក ប៉ូច សោភ័ណ | [redacted] [redacted] |
| Mr. Poch Sophorn<br>អង្គការសម្រុះសម្រួលឯករាជ្យ (IMG)<br>Independent Mediation Organization (IMG) | ក្រុមហ៊ុន សុកហ្វីន<br>CompanySocfin |

ភាគីពាក់ព័ន្ធ

Relevant stakeholders

| តំណាងខាងអង្គការសហប្រជាជាតិ | អាជ្ញាធរឃុំប៊ូស្រាជាអ្នកសង្កេតការ | អាជ្ញាធរស្រុកពេជ្រាដាជាអ្នកសង្កេតការ |
|---|---|---|
| UN-OHCHR Representative | Busra Commune Authority | Pichreada District Authority |
| [redacted]<br>[redacted] | យឿត សារិន<br>Yoeurt Sarin | ខាំ ផងជា<br>Kham Phangchea |

| តំណាងចាស់ទុំភូមិពូទឹត | តំណាងចាស់ទុំភូមិពូលុ | តំណាងចាស់ទុំភូមិប៊ូស្រា |
|---|---|---|
| Representatives of the elders Pu Teut | Representatives of the elders Pu Lu | Representatives of the elders Busra |
| សឹង ត្រាក ក្លីន ចេល | ប្រប់ ម៉ាលី ខែល ស្រេត | ង៉ែល ឆើច |
| Soeng Trak KlinChel | Brorb Maly Khel Sret | Ngel Chheuch |

| | |
|---|---|
| **មេធាវីរបស់សហគមន៍** | **មេធាវីរបស់ភាគីក្រុមហ៊ុន** |
| Attorney at law of the community | Attorney at law of the company |
| **ធឹង ពុទ្ធារិទ្ធ** ThoeungPuthearith — **រុន សារាយ** Run Saray | …………………………… |
| **តំណាងម្ចាស់ជំនួយ** | **អ្នកបកប្រែភាសា** |
| Donor Representative | Translator |
| [redacted] | **ថៃ សុធា** |
| | Thai Sothea |

GO Co., Ltd.